# ប្រវត្តិនៃដំណើរឈានទៅរកឯករាជ្យជាតិពីបារាំងនាឆ្នាំ១៩៥៣

*ដោយ* : **លោក សួ ប៊ុណ្ណារ៉ាត់**
*ប្រធាននាយកដ្ឋានប្រវត្តិវិទ្យានិងវិទ្យាសាស្ត្រនយោបាយ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ប្រទេសកម្ពុជាបានធ្លាប់ស្ថិតនៅក្រោមរបបអាណាព្យាបាលបារាំងអស់រយៈពេល៩០ឆ្នាំ(១៨៦៣-១៩៥៣)។ រាល់ប្រភពឯកសារនានាដែលទាក់ទងនៅក្នុងសម័យនោះ បារាំងបានរក្សាទុកនូវឯកសារដើម (Archives) ជាច្រើនដែលមានចំណាស់តាំងពីចុងសតវត្សរ៍ទី១៩ នៅក្នុងបណ្ណសារដ្ឋានជាតិនៃកម្ពុជានៅក្រុងភ្នំពេញ។ ប៉ុន្តែឯកសារនោះទៀតសោធភាគច្រើនជាភាសាបារាំង ចំណែកឯកសារជាភាសាខ្មែរក៏នៅមិនទាន់មានការផ្សព្វផ្សាយឱ្យទូលំទូលាយនៅឡើយ។ ដូច្នេះហើយបានជាការយល់ដឹងអំពីប្រទេសកម្ពុជា នាសម័យបារាំងស្ថិតនៅជាអាថ៌កំបាំងជាច្រើនអន្លើនៅឡើយ រហូតមកដល់សព្វថ្ងៃនេះ។*

*នៅដំណាក់កាលចុងក្រោយនាសម័យឧដុង្គ សភាពការណ៍ក្នុងស្រុកនៅប្រទេសកម្ពុជាបានធ្លាក់ក្នុងសភាពវឹកវរ ដែលយើងចាត់ទុកជាយុគសម័យអន្ធកាល ពោលគឺកម្ពុជាស្ថិតនៅក្រោមការប្រទាញប្រទង់ពីប្រទេសជិតខាងពីរផ្សេងគ្នា ប៉ែកខាងលិចគឺសៀមនិងប៉ែកខាងកើតគឺអណ្ណាម។ ដោយសារការទទួលរងនូវឥទ្ធិពលនៃសម្ពាធបែបនេះ ទើបព្រះអង្គដួងសម្រេចព្រះទ័យងាកមកទំនាក់ទំនងខាងប្រទេសអឺរ៉ុប (បារាំង)។ ម្យ៉ាងទៀត ទ្រង់បានជ្រាបសភាពការណ៍នៅប៉ែកខាងលិចសៀមមានគម្រោងយកខេត្តបាត់ដំបង សៀមរាប មង្គលបុរី ទន្លេរពៅ ថែមទាំងធ្វើការកៀបសង្កត់ខ្មែរ ហើយលើសពីនោះទៀតមន្ត្រីខ្មែរដែលនៅខេត្តជាប់ព្រំដែននៃប្រទេសសៀម ហាក់បីដូចមិនគោរពព្រះអង្គទៀតផង រីឯនៅប៉ែកខាងកើតអណ្ណាមចេះតែបន្តការត្រួតត្រា កៀបសង្កត់ប្រជាជនខ្មែរកាន់តែធ្ងន់ធ្ងរឡើងៗ និងថែមទាំងបំបាត់អត្តសញ្ញាណជាតិខ្មែរនៅកម្ពុជាក្រោមផងដែរ។*

## ១.ការចាប់ផ្តើមទំនាក់ទំនងបារាំង

ព្រះអង្គដួងទ្រង់បានចាប់ផ្តើម ធ្វើការទំនាក់ទំនងជាមួយបារាំងចាប់តាំងពីឆ្នាំ ១៨៥៣ មកម្លេះ។ ដោយបានទទួលព័ត៌មានពីព្រះតេជគុណ ហ្សង់ក្លូដមីស (Jean Claude Miche) បព្វជិតបារាំងដែលជាមនុស្សស្និតនឹងព្រះអង្គ បានប្រាប់អំពីការទំនាក់ទំនងជាមួយព្រះចៅអធិរាជបារាំង **ណាប៉ូឡេអុងទី៣** (Napoleon III)។ ទើបនៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ ១៨៥៣ ព្រះអង្គដួងបានសរសេរព្រះរាជសារមួយច្បាប់ផ្ញើទៅកាន់ថ្វាយព្រះចៅអធិរាជបារាំង **ណាប៉ូឡេអុងទី៣** (Napoleon III) ដើម្បីសុំមកជួយអន្តរាគមន៍បញ្ចៀសប្រទេសកម្ពុជាចេញពីការកៀបសង្កត់ពីសៀមនិងអណ្ណាម។ ដូច្នេះចាប់ពីឆ្នាំ១៨៥៣ដល់ឆ្នាំ១៨៥៦ គឺជាការចាប់ផ្តើមទំនាក់ទំនងរវាងព្រះបាទអង្គដួង និងព្រះចៅអធិរាជបារាំង **ណាប៉ូឡេអុងទី៣** (Napoleon III) ។ ព្រះអង្គដួងជាព្រះមហាក្សត្រខ្មែរដំបូង ដែលបានផ្តួចផ្តើមគំនិតចង់ឱ្យបារាំងមកជួយការពារប្រទេសកម្ពុជា ឱ្យផុតពីឥទ្ធិពលរបស់ប្រទេសជិតខាងទាំងពីរ គឺប្រទេសអណ្ណាម និងជាពិសេសប្រទេសសៀម។ ការធ្វើទំនាក់ទំនងរបស់ព្រះបាទអង្គដួង ដោយព្រះអង្គព្រួយព្រះទ័យយ៉ាងខ្លាំងចំពោះការបាត់បង់ទឹកដី និងអំពើឈ្លានពានរបស់ប្រទេសទាំងពីរ (សៀមនិងអណ្ណាម)គឺក្នុងបំណងដើម្បីបញ្ចប់ឥទ្ធិពលសៀមមកលើកម្ពុជា។ ព្រះអង្គបានបញ្ជូនមន្ត្រីជាន់ខ្ពស់ខ្មែរពីររូបឈ្មោះ **កុយ** និង **ប៉ែន** (ដែលមានខ្សែលោហិតពីជនជាតិព័រទុយហ្គាល់) ទៅកាន់សិង្ហបុរីជាសម្ងាត់ ដើម្បីនាំព្រះរាជសារលិខិតទៅជូនមន្ត្រីកុងស៊ុលបារាំងដែលត្រូវបញ្ជូនបន្តទៅថ្វាយព្រះចៅអធិរាជបារាំង **ណាប៉ូឡេអុងទី៣** (Napoleon III) ។ បន្ទាប់មកបារាំងបានចាត់ដំណាងរបស់ព្រះអង្គ គឺលោក **សាល ដឺ ម៉ុងទីញី** (Charles de Montigny)ជាការធារីបារាំងឱ្យចុះមក លោកក៏បានមកដល់កំពង់ផែកំពតនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៨៥៦ បានតាក់តែងអត្តបទអនុសញ្ញាពាណិជ្ជកម្ម និងសាសនា ដើម្បីស្ថាបនាទំនាក់ទំនងជាមួយកម្ពុជា។ ប៉ុន្តែដោយមានការកៀបសង្កត់ពីសៀម ព្រះបាទអង្គដួង មិនបានយាងទៅឡាយព្រះហស្តលេខាលើអនុសញ្ញានោះឡើយ។ នេះជាការប៉ុនប៉ងលើកដំបូងរបស់ព្រះរាជាខ្មែរ ក្នុងការបញ្ចប់ឥទ្ធិពលសៀមមកលើកម្ពុជា ប៉ុន្តែមិនបានសម្រេច។ ដូចដែលយើងបានដឹងរួចមកហើយថា នៅក្នុងឆ្នាំ ១៨៥៣ ព្រះបាទអង្គដួងបានផ្ញើព្រះរាជសារលើកទី១ទៅថ្វាយព្រះចៅអធិរាជ **ណាប៉ូឡេអុងទី៣** (Napoleon III) ដែលមានខ្លឹមសារថា៖ «ពួកបេសកបព្វជិតបារាំងហ្សង់ក្លូដមីស (Jean Claude Miche) បានប្រាប់ឱ្យយើងដឹងថា អធិរាជបារាំងមានចិត្តសប្បុរសចំពោះគ្រប់

ប្រជាជាតិ ព្រះអង្គជួយការពារប្រជាជាតិទាំងនោះ ដើម្បីធានាស្ថិរភាព និងសុខុមាលភាព ដោយមិនធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍ជនម្ចាស់ស្រុក និងថាអធិរាជបារាំងល្អ ពុំមានការប៉ុនប៉ងដូចព្រះមហាក្សត្រដ៏ទៃទៀតនៃទ្វីបអឺរ៉ុប ដែលគិតតែជិះជាន់ប្រទេសដទៃ។ ដោយហេតុនេះយើងមានសេចក្ដីរីករាយ នឹងចងសម្ព័ន្ធភាពមួយរឹងមាំជាមួយព្រះចៅអធិរាជ ដែលនឹងធ្វើឱ្យប្រទេសរបស់យើងធំនិងសម្បូណ៌ ដើម្បីសេចក្ដីរុងរឿងរបស់ប្រទេសយើង។ ក្រោយមកទៀតនៅឆ្នាំ១៨៥៦ ព្រះអង្គបានផ្ញើព្រះរាជសារជាលើកទី២ ទៅថ្វាយព្រះចៅអធិរាជបារាំង **ណាប៉ូឡេអុងទី៣** (Napoleon III) ទៀតដែលមានខ្លឹមសារថា៖«ចាប់ពីឆ្នាំ១៨៤៦ ស្ដេចនៅកូសាំងស៊ីនបានប្រកាសថា បណ្ដាខេត្តដែលគេយកបានពីកម្ពុជានោះមិនត្រូវស្ដាប់បង្គាប់ខ្ញុំ និងមិនត្រូវបង់សួយសាអាករមកឱ្យខ្ញុំទៀតទេ។ លើសពីនេះគេបានរាំងមិនឱ្យធ្វើពាណិជ្ជកម្ម នៅក្នុងប្រទេសខ្ញុំរួមទាំងនៅតាមកំពង់ផែនានាផងដែរ។ នេះហើយជាស្ថានភាពជាក់ស្ដែងនៃព្រះរាជាណាចក្រកម្ពុជា។ សូមព្រះអង្គទ្រង់ជ្រាបនូវខេត្តទាំងនោះ ដែលមានឈ្មោះដូចតទៅ៖ ខេត្តដូនណៃ ដែលបានបាត់ជាង២០០ឆ្នាំមកហើយ ប៉ុន្តែខេត្តជាច្រើនទើបបានបាត់ក្នុងពេលថ្មីៗនេះគឺ៖ ខេត្តព្រៃនគរ លង់ហោ ផ្សារដែក មេស ព្រះត្រពាំង អុងម៉ ក្រមួនស ទឹកខ្មៅ ពាម ឬហាទៀង កោះត្រល់ និងកោះត្រឡាច។ ប្រសិនបើដោយចៃដន្យ ពួកអណ្ណាមប្រគល់ខេត្តណាមួយថ្វាយព្រះអង្គ សូមព្រះអង្គកុំទទួលពីព្រោះគឺជាខេត្តរបស់កម្ពុជាទេ។ សូមព្រះអង្គមេត្តាករុណាដល់ខ្ញុំ និងប្រជាជនខ្ញុំផង ដើម្បីបញ្ចប់នូវការបាត់បង់នេះ»។

ព្រះចៅអធិរាជបារាំង **ណាប៉ូឡេអុងទី៣** (Napoleon III) ក្រោយពីបានដឹងអំពីរឿងរ៉ាវតាមរយៈព្រះរាជសាររបស់ព្រះអង្គដួងមក ទើបនាំឱ្យមានការបង្កើតសន្ធិសញ្ញាស្ដីពីអាណាព្យាបាលបារាំងនៅកម្ពុជានៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។

យើងគួរគប្បីស្វែងយល់តើអ្វីទៅជាអាណានិគមនិងអ្វីទៅជាអាណាព្យាបាល?

⇨**អាណានិគម៖** មានន័យពីរ៖

-ទឹកដីដែលកាន់កាប់និងគ្រប់គ្រងផ្ទាល់ដោយមហាអំណាចបរទេសណាមួយ។ ឧទាហរណ៍ កូសាំងស៊ីន(នៅឥណ្ឌូចិន) ជាអាណានិគមរបស់បារាំង (នៅអឺរ៉ុប) ចាប់ពីឆ្នាំ១៨៥៩ដល់ឆ្នាំ១៩៤៩។

-ទឹកដីកាន់កាប់និងគ្រប់គ្រងផ្ទាល់ដោយប្រជាជាតិមួយ ដែលនៅក្រៅពីព្រំដែនរបស់ខ្លួន និងនៅតែផ្សារភ្ជាប់ជាមួយមាតុជាតិដោយរក្សាទំនាក់ទំនងជិតស្និទ្ធខាង

នយោបាយនិងសេដ្ឋកិច្ច។ ឧទាហរណ៍ អាណានិគមទាំង១៣នៅអាមេរិកខាងជើង។

➾**អាណាព្យាបាល៖** របបកើតពីកិច្ចព្រមព្រៀងដែលរដ្ឋពីរធ្វើការបែងចែកសមត្ថកិច្ចមិនស្មើគ្នា។ រដ្ឋអាណាព្យាបាល (Etat protecteur) ទទួលខុសត្រូវទាំងស្រុងក្នុងកិច្ចការអន្តរជាតិ។ រដ្ឋក្រោមអាណាព្យាបាល (Etat protégé) បន្តគ្រប់គ្រងរដ្ឋនៅក្រោមការត្រួតពិនិត្យ ពីរដ្ឋអាណាព្យាបាលនៅក្នុងរដ្ឋបាលមួយបែបហៅថា «**រដ្ឋបាលមិនផ្ទាល់**»(Administration indirecte)។ ឧទាហរណ៍ នៅសម័យបារាំង(១៨៦៣-១៩៥៣) ប្រទេសបារាំងជារដ្ឋអាណាព្យាបាល ឯប្រទេសកម្ពុជាជារដ្ឋក្រោមអាណាព្យាបាល។

ព្រះអង្គដួង ទ្រង់មានព្រះរាជបំណងមិនចង់ឱ្យប្រទេស ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សៀម ជាហេតុធ្វើឱ្យព្រះអង្គសម្រេចព្រះទ័យងាកមកបារាំង គឺបានសេចក្តីថាការប្តូរពីអាណាព្យាបាលសៀមមកអាណាព្យាបាលបារាំងវិញ។




ប្រភព: បណ្ឌិតសភាចារ្យ ស៊ន សំណាង

**សន្ធិសញ្ញាបារាំង-កម្ពុជា ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣** ជាសន្ធិសញ្ញាអាណាព្យាបាលដែលត្រូវបាន ចុះហត្ថលេខា នៅថ្ងៃទី ១១ ខែសីហា ឆ្នាំ១៨៦៣ នៅព្រះរាជវាំងឧដុង្គ រវាងព្រះបាទនរោត្តម និង លោកឧត្តមនាវី **ដឺឡាក្រង់ឌីយែ** (De la Grandière) ដែលជាទេសាភិបាលបារាំងនៅកូសាំងស៊ីន (Gouverneur de la Cochinchine)។ សន្ធិសញ្ញាដែលមានចំនួន១៩មាត្រានោះ មានចែងជាអាទិ៍ថា៖ព្រះចៅអធិរាជបារាំងផ្តល់នូវកិច្ច

ការពាររបស់ខ្លួនចំពោះព្រះរាជាកម្ពុជា(មាត្រា១)។ ព្រះចៅអធិរាជបារាំងដែលទទួលស្គាល់អធិបតេយ្យនៃព្រះរាជាកម្ពុជានោះ សន្យាថានឹងជួយរក្សាសណ្តាប់ ធ្នាប់ និងភាពស្ងប់ស្ងាត់នៅក្នុងប្រទេស ព្រមទាំងការពារកម្ពុជា ទល់នឹងរាល់ការវាយប្រហារពីខាងក្រៅ ជួយកម្ពុជាក្នុងការទារពន្ធដារពាណិជ្ជកម្ម និងផ្តល់នូវភាពងាយស្រួលក្នុងការស្ថាបនាគមនាគមន៍រវាងកម្ពុជា និងសមុទ្រ(មាត្រា១៦)។

***អនុសញ្ញាបារាំង-កម្ពុជា ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤*** ជាអនុសញ្ញាដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ នៅព្រះរាជវាំងភ្នំពេញ រវាងព្រះបាទ ***នរោត្តម*** និងលោក សាល ថមសុន (Charles Thomson) ដែលជាទេសាភិបាលបារាំងនៅកូសាំងស៊ីន។

អនុសញ្ញាដែលមានចំនួន១១មាត្រានោះ មានចែងជាអាទិ៍ថា៖

-ព្រះរាជាកម្ពុជាទទួលយករាល់កំណែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលរដ្ឋាភិបាលសាធារណរដ្ឋបារាំងយល់ថា នឹងមានប្រយោជន៍ដល់ដំណើរការអនុវត្តរបបអាណាព្យាបាលរបស់ខ្លួននៅ ពេលអនាគត(មាត្រា១)។

-ព្រះរាជាកម្ពុជានឹងបន្តគ្រប់គ្រងរដ្ឋនិងដឹកនាំរដ្ឋបាល ដូចក្នុងអតីតកាលលើកលែងតែការកម្រិតនានាដែល មានចែងនៅក្នុងអនុសញ្ញានេះ(មាត្រា២)។

-មន្ត្រីខ្មែរនឹងនៅបន្តគ្រប់គ្រងអាណាខេត្តក្រោមការត្រួតពិនិត្យពីអាជ្ញាធរបារាំង លើកលែងតែកិច្ចការណាដែលទាក់ទងនឹងការធ្វើបញ្ជីនិងការទារពន្ធដារ ពន្ធគយ វិភាគទានមិនផ្ទាល់ សាធារណការ និងជាទូទៅកិច្ចការដែលតម្រូវឱ្យមានការដឹកនាំតែមួយ ឬការប្រើប្រាស់វិស្វករឬភ្នាក់ងារ អឺរ៉ុប (មាត្រា៣)។

- ទាសភាពត្រូវលុបចោល នៅលើផ្ទៃនៃព្រះរាជាណាចក្រកម្ពុជាទាំងមូល(មាត្រា៨)។

ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ បារាំងមិនដាក់ការកៀបសង្កត់លើខ្មែរទេ ប៉ុន្តែ២១ឆ្នាំក្រោយមកគឺនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ បារាំងចាប់ផ្តើមសាកល្បងដណ្តើមយកអំណាចពីព្រះមហាក្សត្រខ្មែរ តាមរយៈនៃការធ្វើកំណែទម្រង់លើអនុសញ្ញាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ដែលចែងអំពីការធ្វើកំណែទម្រង់លើផ្នែករដ្ឋបាល តុលាការ ហិរញ្ញវត្ថុ ការធ្វើកំណែទម្រង់នេះក្នុងបំណង ប្រមូលយកអំណាចទាំងអស់ទៅកាន់កាប់ដំណាងឱ្យព្រះមហាក្សត្រខ្មែរ។ ការដណ្តើមអំណាចនេះគឺមិនទទួលបានជោគជ័យឡើយ ពីព្រោះវាជាដើមហេតុនាំឱ្យមានកើតការបះបោរពីឆ្នាំ១៨៨៥ ដល់ឆ្នាំ១៨៨៦ ទើបចប់ ធ្វើឱ្យបារាំងបន្ធូរបន្ថយការប៉ុនប៉ងដណ្តើមអំណាចពីព្រះមហាក្សត្រខ្មែរ ក៏

ផាកមកចរចាស្រុះស្រួលគ្នាឡើងវិញនៅឆ្នាំ ១៨៨៦។ ក៏ប៉ុន្តែបើយើងពិនិត្យឱ្យស៊ីជម្រៅទៅ សន្ធិសញ្ញាបារាំង-កម្ពុជា ថ្ងៃទី១១ ខែសីហា ឆ្នាំ ១៨៦៣ គឺជារបបអាណាព្យាបាលទទួលយកបាន (Protectorat acceptable) ឯអនុសញ្ញា បារាំង-កម្ពុជានាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ គឺបានប្តូរមកជារបបអាណាព្យាបាលតឹងរឹង (Protectorat très dur) ពីព្រោះប្រទេសកម្ពុជានៅមានឋានៈជារដ្ឋ ចំណែកឯអាណាណានិគមកូសាំងស៊ីនមានឋានៈត្រឹមជាខេត្តមួយរបស់បារាំង[1]។

ឯករាជ្យជាស្ថានភាពនៃប្រទេសមួយដែលមិនស្ថិតនៅក្រោមប្រទេសមួយទៀត ហើយបើមានការកៀបសង្កត់ នោះប្រាកដជាមានការរើបម្រាស់ជាមិនខាន។ ដោយឡែកប្រទេសកម្ពុជាដើមចមដែលនាំឱ្យមានការទាមទារឯករាជ្យ មកពីយើងស្ថិតនៅក្រោមការគ្រប់របស់បារាំង(ថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ដល់ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣)។ ក្រោយពីសង្គ្រាមលោកលើកទី២ ការគ្រប់គ្រងរបស់បារាំងមានការប្រែប្រួលជាបន្តបន្ទាប់ ហើយក៏ជាហេតុធ្វើឱ្យប្រទេសមួយចំនួនឈានទៅការផ្ទុះនូវចលនាទាមទារឯករាជ្យ ពីមហាអំណាចអាណានិគមទាំងនោះនៅក្នុងក្របខណ្ឌពិភពលោក។ ដោយ ឡែកនៅឧបទ្វីបឥណ្ឌូចិន ក៏មានចលនាទាមទារឯករាជ្យជាបន្តបន្ទាប់។ ពាក្យឯករាជ្យជាពាក្យស្នូលនៃឯករាជ្យជាតិ ពិសេសគឺឯករាជ្យនយោបាយ។ ជាទិដ្ឋភាពរួម ឯករាជ្យ គឺជាសេរីភាពរបស់ប្រទេសមួយ រួចផុតពីការត្រួតត្រារបស់ប្រទេសមួយទៀត បានសេចក្តីថាមានប្រទេសពីរ។ តួយ៉ាងដូចជាក្នុងបរិបទប្រទេសកម្ពុជា បារាំងជាអ្នកគ្រប់គ្រងយើង ហើយយើង(កម្ពុជា) ជាអ្នកទាមទារឱ្យមានសេរីភាពរួចផុតពីការត្រួតត្រារបស់បារាំង។ ជាការពិតតាមទិដ្ឋភាពប្រវត្តិសាស្ត្រ កម្ពុជាយើងធ្លាប់ទទួលបានឯករាជ្យ៣លើកពីបារាំងមានដូចជា៖

### ៙.ឯករាជ្យលើកទី១ ឆ្នាំ១៩៤៥

ឧត្តមសេនីយ៍ **ស៊ុឈីហាស៊ិ** ជនជាតិជប៉ុនបានដឹកនាំកងទ័ពវាយលុកចូលកាន់កាប់ចាប់បារាំង នៅឥណ្ឌូចិនបារាំងនៅរាត្រីថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៤៥ ព្រឹត្តិការណ៍នេះដែលយើងហៅថាពលប្រហារយោធាជប៉ុនមកលើបារាំង ហើយឆ្លៀតពេលនោះកម្ពុជាបានប្រកាសឯករាជ្យខ្មែរជាលើកដំបូងពីបារាំង គឺពេលដែលជប៉ុនដេញបារាំង ដែលកាលនោះសម្តេចព្រះ

---

[1] បណ្ឌិតសភាចារ្យ ស៊ន សំណាង សិក្ខាសាលាទី១៩១ ថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤

**នរោត្តម សីហនុ** នៅក្នុងដំណែងជានាយករដ្ឋមន្ត្រី។ ក្នុងពេលនោះដែរសម្តេចព្រះ **នរោត្តម សីហនុ** បានប្រកាសឯករាជ្យពីបារាំងជាលើកដំបូងគឺថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៤៥ ឯករាជ្យនេះមានរយៈពេល៧ខែ៤ថ្ងៃ។ ចាប់ពីឆ្នាំ១៨៦៣ដល់ឆ្នាំ១៩៤៥ កម្ពុជាបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់បារាំង គឺអស់រយៈពេល៨២ឆ្នាំ។ ទើបនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៤៥ សម្តេចព្រះ **នរោត្តម សីហនុ** បានបង្កើតរដ្ឋាភិបាលឯករាជ្យ ដែលព្រះអង្គជានាយករដ្ឋមន្ត្រីមានរយៈពេល៤ខែនិង២៥ថ្ងៃ (ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៤៥ដល់ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៤៥) ហើយបន្ទាប់មកលោក **សឺង ង៉ុកថាញ់** បានឡើងធ្វើជានាយករដ្ឋមន្ត្រីបន្តគឺបានត្រឹមរយៈពេល២ខែ២ថ្ងៃ (ថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៤៥ ដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៤៥)។ លុះមកដល់ថ្ងៃទី១៦ ខែតុលា ឆ្នាំ១៩៤៥ បារាំងបានវិលត្រឡប់មកវិញ។ ឯករាជ្យលើកទី១ គឺពិតជាមានសារៈ សំខាន់ណាស់ដែលយើងគួរចងចាំ ហើយពលប្រហារយោធារបស់ជប៉ុន បានធ្វើឱ្យប៉ះពាល់និងជះឥទ្ធិពលទៅលើនយោបាយគ្រប់គ្រងរបស់បារាំងផងដែរ។ ៣ថ្ងៃក្រោយពេលពលប្រហារយោធាជប៉ុន គឺនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៤៥ រដ្ឋាភិបាលបានប្រកាសឯករាជ្យលើកទី១។ បើយើងពិចារណាឱ្យបានស៊ីជម្រៅឯករាជ្យលើកទី១ ពិតជាមានសារៈសំខាន់សម្រាប់ជាប្រវត្តិសាស្ត្រ។ រហូតមកដល់បច្ចុប្បន្ន ខ្មែរយើងមិនសូវចាប់អារម្មណ៍នឹងឯករាជ្យជាតិលើកទី១ ឆ្នាំ១៩៤៥ នោះទេ គឺគេនាំគ្នាចាប់ អារម្មណ៍តែឯករាជ្យឆ្នាំ១៩៥៣ អាចថាឯករាជ្យជាតិលើកទី១ប្រហែលមកពីខ្វះឯកសារ។ ក្រោយសង្គ្រាមលោកលើកទី២ បារាំងវិលគ្រប់គ្រងកម្ពុជាដូចពីមុន។ តាមកិច្ចព្រមព្រៀងបណ្តោះអាសន្ន (Modus Vivendi) ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៤៦ នៅថ្នាក់ជាតិមាន«ស្នងការសាធារណរដ្ឋបារាំង» មកជំនួស«រេស៊ីដង់ជាន់ខ្ពស់»។ នៅថ្នាក់ក្រោមជាតិ «ទីប្រឹក្សាតំបន់» មកជំនួស «រេស៊ីដង់រួមខេត្ត» (គឺចៅហ្វាយខេត្តបារាំង)។

### ៚-ឯករាជ្យលើកទី២ ឆ្នាំ១៩៤៩

នៅមុនឆ្នាំ១៩៤៩ គឺនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៤៨ ប្រទេសបារាំងបានប្រកាសឯករាជ្យប្រទេសកម្ពុជា ក្នុងសហភាពបារាំង តែឯករាជ្យនេះជាឯករាជ្យតែសម្បកគឺគ្មានខ្លឹមសារអ្វីឡើយ។

ទើបក្រោយមកសន្ធិសញ្ញាបារាំង-កម្ពុជា នាថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ ជាសន្ធិសញ្ញាដែលត្រូវបានចុះហត្ថលេខា នៅប្រាសាទអេលីហ្សេ (ប៉ារីស) រវាងបារាំងនិងកម្ពុជា ដែលមាន២០មាត្រា។ មាត្រា១ ចែងថាសាធារណរដ្ឋបារាំងទទួលស្គាល់ព្រះរាជាណាចក្រកម្ពុជា ថាជារដ្ឋ

ឯករាជ្យ[2]។ ព្រះរាជាណាចក្រកម្ពុជាអះអាងជាថ្មី នូវការចូលជាសមាជិករបស់ខ្លួន ក្នុងសហភាពបារាំងក្នុងឋានៈជា «សមាគតរដ្ឋ»។ តាមច្បាប់អន្តរជាតិ ការទទួលស្គាល់ជាផ្លូវការរបស់បារាំង នូវឯករាជ្យនៃកម្ពុជាមានតាំងពីឆ្នាំ ១៩៤៩[3]។

នៅពេលនោះសភាបារាំងបានលុបចោលសន្ធិសញ្ញាថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ហើយក៏បានផ្តល់ឯករាជ្យមកឱ្យខ្មែរ តែជាតុពិតឯករាជ្យនោះជាឯករាជ្យមិនពេញលេញ គឺមានតែនៅលើក្រដាស គឺយើងនៅខ្វះអធិបតេយ្យភាពខាង ***តុលាការ នគរបាល បញ្ជាការសឹក ការទូត ការត្រួតត្រារូបិយបណ្ណ*** និង ***ខាងបោះធនប័ត្រ*** ជាដើម។ កង្វះខាតទាំងនោះហើយទើបនាំឱ្យមានការទាមទារមកបង្គ្រប់នូវចំណុចដែលនៅខ្វះ ដែលនឹងឈានទៅការបង្កើតចលនាទាមទារបង្គ្រប់នូវចំណុចដែលនៅខ្វះខាត។ តាមព្រះរាជប្រសាសន៍ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់បានប្រកាសនិងសន្យាជាឱឡារិកដល់ប្រជារាស្ត្ររបស់ព្រះអង្គថា ទ្រង់និងរកនូវឯករាជ្យបរិបូរណ៍ ជូនមាតុភូមិឱ្យខាងតែបានក្នុងរវាង៣ឆ្នាំយ៉ាងយូរ[4]។ ការសន្យានេះប្រសិនបើបែរជាមិនបានសម្រេចទៅវិញ ព្រះអង្គទ្រង់ប្រកាសថា ព្រះអង្គយល់ព្រមឱ្យជាតិជំរះព្រះអង្គ ដោយយកព្រះអង្គទៅដាក់ទោសតាមចិត្ត ហើយព្រះអង្គសុខព្រះទ័យស៊ូប្តូរព្រះជន្ម[5]។ នៅឆ្នាំ១៩៤៩ ព្រះអង្គបានទាមទាររហូតទទួលស្វ័យភាព ខាងសឹកនូវខេត្តចំនួនពីរគឺខេត្តសៀមរាបនិងកំពង់ធំ។ ក្រោយមកទៀតនៅឆ្នាំ១៩៥២ព្រះអង្គទទួលខេត្តមួយបន្ថែមទៀតគឺខេត្តបាត់ដំបង។

តាមសន្ធិសញ្ញានេះ សហភាពរូបិយវត្ថុនិងគយ (Union monétaire et douanière) បានភ្ជាប់កម្ពុជា ជាមួយសមាគតរដ្ឋផ្សេងទៀតនៅឥណ្ឌូចិន គឺវៀតណាម(ខាងត្បូង)និងឡាវ។ ផលប្រយោជន៍ដែលប្រទេសកម្ពុជា បានទទួលនោះមានដូចជា៖

[2] ប្រវត្តិសង្ខេបនៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់កម្ពុជា ភ្នំពេញឆ្នាំ១៩៥៦ ទំព័រទី១

[3] ព្រះរាជសាសន៍សម្តេចព្រះ នរោត្តម សីហនុ ឧបយុវរាជ នាយករដ្ឋមន្ត្រី ទ្រង់ថ្លែងក្នុងឱកាសពិធីបុណ្យរំលឹកឯករាជ្យជាតិប្រចាំឆ្នាំទី៥ កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៨ ទំព័រទី៦

[4] ប្រវត្តិសង្ខេបនៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់កម្ពុជា ភ្នំពេញឆ្នាំ១៩៥៦ ទំព័រទី២

[5] ផែនការកសាងឯករាជ្យ ប្រទេសកម្ពុជានៃព្រះសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ភ្នំពេញឆ្នាំ១៩៥៣ ទំព័រទី២

ក-អ្នកអង្គម្ចាស់ **ពីងពាងយុគន្ធរ** ដែលជាម្ដាយមីងរបស់សម្ដេចព្រះ **នរោត្តម សីហនុ** បានក្លាយជាអនុប្រធានសភានៃសហភាពបារាំង។

ខ-ប្រទេសកម្ពុជាមានសិទ្ធិចុះកិច្ចព្រមព្រៀងអន្តរជាតិទាក់ទងនឹងផលប្រយោជន៍ផ្ទាល់ខ្លួន។

គ-ព្រះមហាក្សត្រខ្មែរមានការទទួលស្គាល់តាមអង្គច្បាប់ពីរដ្ឋចំនួន៣៥ ដែលមានសហរដ្ឋអាម៉េរិក និងចក្រភពអង់គ្លេស នៅក្នុងនោះព្រះអង្គបានដាក់ស្ថានទូតនៅក្នុងប្រទេសមួយចំនួនហើយប្រទេសកម្ពុជា បានចូលរួមដោយពេញសិទ្ធិនៅក្នុងសន្និសីទក្រុងសានហ្វ្រានស៊ីស្កូ នាថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៥១ ដោយបានចុះហត្ថលេខាលើសន្ធិសញ្ញាសន្តិភាពជាមួយប្រទេសជប៉ុន។

ទោះជាយ៉ាងនេះក្ដី ក៏បារាំងនៅរក្សាសមត្ថកិច្ចមួយចំនួន ដោយផ្ដាច់មុខដូចជាបញ្ហាការខាងកង កម្លាំងប្រដាប់ អាវុធ ខាងសន្តិសុខ ជាដើម។

### ៙.ឯករាជ្យលើកទី៣ ឆ្នាំ១៩៥៣

ឯករាជ្យជាស្ថានភាពប្រទេសមួយដែលមិនស្ថិតនៅក្រោមប្រទេសមួយផ្សេងទៀត។ ឯករាជ្យថ្ងៃទី៩ ខែវិច្ឆកា ឆ្នាំ១៩៥៣ គឺជាឯករាជ្យផ្លូវការណ៍និងជាក់លាក់ ដែលសម្ដេចព្រះ **នរោត្តម សីហនុ** ជាអម្ចាស់ជីវិតលើត្បូង ទ្រង់បានពុះពារតស៊ូកាត់ឧបសគ្គយ៉ាងលំបាកលំបិនដើម្បីបុព្វហេតុជាតិនិងមាតុភូមិរបស់យើង។ ទម្រាំទទួលបានឯករាជ្យបរិបូណ៌ព្រះអង្គបានធ្វើព្រះរាជសកម្មភាពទាំងក្នុងប្រទេស និងក្រៅប្រទេស។ ក្រោយមកព្រះអង្គត្រូវបានប្រជានុរាស្ត្រថ្វាយព្រះឋានៈព្រះអង្គជា *ព្រះបិតាឯករាជ្យជាតិ*។ តាមសេចក្ដីស្នើសុំពីពួកតំណាងរាស្ត្រ ដែលជាសមាជិកនៃក្រុមប្រឹក្សាជាតិរាជរដ្ឋាភិបាល បានលើកតម្កល់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុ** ជា *ព្រះមហាវីរបុរសជាតិ* តាមព្រះរាជក្រិត្យលេខ៩៥៣ ន.ស.ចុះថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៥៣[6]។

ដើម្បីជាការចងចាំនូវព្រះរាជស្នាព្រះហស្ដដ៏ឧត្តុងឧត្តម នៃការទាមទារឯករាជ្យពីអាណាព្យាបាលបារាំង រាជរដ្ឋាភិបាលបានកសាងវិមានឯករាជ្យ និង ត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់នៅឆ្នាំ១៩៥៨ ក្នុងរាជ្យព្រះបាទ **នរោត្តម សុរាម្រិត** (១៩៥៥-១៩៦០) ជាព្រះវរាជបិតា របស់សម្ដេចព្រះ **នរោត្តម សីហនុ**។ វិមានឯករាជ្យនេះ ក៏ជានិមិត្តរូបបញ្ជាក់ថាប្រទេសកម្ពុជា បានទទួលឯករាជ្យពីប្រទេសបារាំង នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ផងដែរ។

6 ប្រវត្តិសង្ខេប នៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់ប្រទេសលម្ពុជា ឆ្នាំ..? ទំព័រទី១៨

ប្រទេសកម្ពុជាតែងតែប្រារព្ធទិវាបុណ្យឯករាជ្យជាតិនេះ ដែលមានពិធីប្រទានភ្លើងទៀនជ័យរំឭកដឹងគុណអ្នកស្នេហាជាតិ ដែលបានពលីជីវិត ដើម្បីឯករាជ្យ ពីពួកអាណាព្យាបាលបារាំង ហើយពិធីបុណ្យត្រូវបានធ្វើឡើងជារៀងរាល់ឆ្នាំ នៅថ្ងៃទី៩ ខែវិច្ឆិកា និងបញ្ចប់នៅថ្ងៃទី១១ ខែវិច្ឆិកា ជាកំណត់។ ថ្ងៃទី៩ ខែវិច្ឆិកានេះ រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឱ្យសិស្សានុសិស្ស និស្សិត កម្មករ និយោជិត និងមន្ត្រីរាជការ បានឈប់សម្រាកផងដែរ ដើម្បីចូលរួមអបអរសាទរ។

**២.ដំណាក់កាលនៃការប្រគល់អំណាចរបស់បារាំងមកឱ្យកម្ពុជា**

ការចរចារជាមួយបារាំងដែលប្រព្រឹត្តិទៅនៅរាជធានីភ្នំពេញមានជាហូរហែ ទម្រាំបារាំងប្រគល់ អំណាចមកឱ្យខ្មែរ ហើយការប្រគល់អំណាចនេះទៀតសោត មានជាដំណាក់កាលៗដូចខាងក្រោមៈ

➥ថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ ការចុះហត្ថលេខាលើសេចក្តីព្រមព្រៀង ស្តីអំពី ការផ្ទេរអំណាចតុលាការ

➥ថ្ងៃទី២៩ ខែសីហា ឆ្នាំ១៩៥៣ ការចុះហត្ថលេខាលើសេចក្តីព្រមព្រៀង ស្តីអំពី ការផ្ទេរអំណាចនគរបាល(ប៉ូលិស)មកឱ្យរដ្ឋាភិបាលកម្ពុជាវិញ

➥ថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៥៣ ការចុះហត្ថលេខាលើសេចក្តីព្រមព្រៀង ស្តីអំពីការប្រគល់អធិបតេយ្យភាព ខាងសេនាយោធាក្នុងប្រទេសទាំងមូលមកឱ្យរដ្ឋាភិបាលកម្ពុជាវិញ

**ឯករាជ្យជាតិកម្ពុជាលើកទី៣ ដែលមានខ្លឹមសារសង្ខេប ដូចតទៅៈ**

➥នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ ព្រះបាទ **នរោត្តម សីហនុ** បានប្រកាសនូវ«ផែនការទាមទារឱ្យបានឯករាជ្យជាតិទាំងស្រុង» យ៉ាងយូរត្រឹម៣ឆ្នាំ។ មួយថ្ងៃបន្ទាប់មកគឺនៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ១៩៥២ មានខិត្តប័ណ្ណមតិមហាជនដែលបាចចេញពីរថយន្តហ្ស៊ីបនៃកងទ័ពបារាំង។ ដែលមានខ្លឹមសារបង្ហាញអំពីការគាំទ្ររបស់ប្រជារាស្ត្រខ្មែរ ចំពោះផែនការទាមទារឯករាជ្យរបស់ព្រះ **នរោត្តម សីហនុ**។

**៣.ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យពីបារាំង**

ជាព្រះរាជបេសកកម្មមួយ យ៉ាងលំបាកដែលសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់បានលះបង់ព្រះកាយពល និងព្រះបញ្ញាញាណយ៉ាងខ្លាំងក្លាបំផុត ដើម្បីទាមទារឯករាជ្យឱ្យរួចផុតពីការគ្រប់គ្រងរបស់បារាំង។ ចលនាទាមទារឯករាជ្យដែលព្រះអង្គបានធ្វើគឺមាននៅក្រៅប្រទេសផង និងនៅក្នុងប្រទេសផងៈ

⇨នៅក្រៅប្រទេស

ចាប់ពីថ្ងៃទី៩ ខែកុម្ភៈ ដល់ដើមខែមិថុនា ឆ្នាំ ១៩៥៣ គឺជាថ្ងៃដែលដ៏វិសេសថ្ងៃថ្លា ដែលត្រូវបានចារឹកក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ព្រោះជាថ្ងៃដែលសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់បានធ្វើព្រះរាជសកម្មភាពទាមទារឯករាជ្យ។ ព្រះអង្គបានយាងចេញពីព្រះរាជាណាចក្រកម្ពុជាទៅប្រទេសបារាំង ដើម្បីទៅជួបប្រមុខរដ្ឋបារាំង។ ដោយសារតែប្រទេសបារាំង មិនព្រមប្រគល់ឯករាជ្យបរិបូណ៌ដល់មកប្រទេសកម្ពុជា ទើបព្រះអង្គចាប់ផ្តើមធ្វើព្រះរាជសកម្មភាពទាមទារឯករាជ្យ ដោយយាងចេញទៅក្រៅប្រទេសដូចជាយាងទៅប្រទេសបារាំង,កាណាដា, សហរដ្ឋអាម៉េរិក, ជប៉ុន និងថៃជាដើម។ យាងចេញពីប្រទេសបារាំង ព្រះអង្គបានបន្តទៅកាណាដា និងសហរដ្ឋអាម៉េរិក នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៣។ យាងត្រឡប់ពីជប៉ុន នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៣ និងយាងបន្តទៅប្រទេសថៃនៅថ្ងៃទី១៣ ខែមិថុនា ឆ្នាំ១៩៥៣។ ព្រះរាជសកម្មភាពនៅក្រៅប្រទេសមានដូចជាៈ

៚នៅថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៥៣ ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** បានយាងចាកចេញពីព្រះរាជាណាចក្រកម្ពុជា ឆ្ពោះទៅកាន់ប្រទេសបារាំង ដើម្បីទាមទារឯករាជ្យរបស់កម្ពុជាជាមួយប្រមុខរដ្ឋបារាំង។

៚ថ្ងៃទី៥ខែមីនាឆ្នាំ១៩៥៣នៅជីឡាណាពូល ប្រទេសបារាំង ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** បានផ្ញើព្រះរាជសារលិខិតមួយច្បាប់ជូនចំពោះលោក វ៉ាំងសង់ អូរីយ៉ូល ប្រធានាធិបតីនៃ សាធារណៈរដ្ឋបារាំង បញ្ជាក់ពីភាពចាំបាច់សំដៅធ្វើឱ្យបារាំងពង្រីកក្របខ័ណ្ឌឯករាជ្យខ្មែរ។ ភ្ជាប់នឹងព្រះរាជសារលិខិតនេះ មានការសិក្សាគ្រប់គ្រាន់ ដោយមានទឡ្ហីករណ៍សម្អាងបញ្ជាក់ពីការទាមទាររបស់ទ្រង់ និង ការផ្តល់យោបល់ពីបែបបទផ្ទេរអំណាចជាយថាហេតុ ។

៚នៅណាពូល ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៥៣ បន្ទាប់មកនៅហ្វុងតែនណាប្លូ ថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៥៣ ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** បានសរសេរព្រះរាជសារលិខិតចំនួន២ច្បាប់បន្តទៀត ផ្ញើជូនលោក វ៉ាំងសង់ អូរីយ៉ូល និងរដ្ឋាភិបាលបារាំង ដើម្បីបំពេញបន្ថែមលើទស្សនៈរបស់ព្រះអង្គទាក់ទងទៅនឹងឯករាជ្យខ្មែរ និងដើម្បីស្នើឱ្យរដ្ឋាភិបាលបារាំង ប្រញាប់ប្រញាល់ដោះស្រាយបញ្ហានេះ។

៚នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៥៣ ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** បានចាកចេញពីប្រទេសបារាំង ឆ្ពោះទៅកាន់ប្រទេសកាណាដា និងសហរដ្ឋអាម៉េរិក ដែលនៅទីនោះព្រះអង្គបានធ្វើយុទ្ធនាការឃោសនាដើម្បីឯករាជ្យរបស់ប្រទេសព្រះអង្គ។

៚សេចក្តីថ្លែងការណ៍របស់ ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** ត្រូវបានចុះផ្សាយ

ដោយកាសែតដ៏ធំ «ដឺ ញូវយ៉កថែម» របស់សហរដ្ឋអាម៉េរិកនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៥៣ ធ្វើឱ្យលាន់ឮខ្ទរខ្ទារពិភពលោកទាំងមូលមានសេចក្ដីរំជួល ហើយបានបង្ខំឱ្យរដ្ឋាភិបាលបារាំងទទួលយល់ព្រម ធ្វើការចរចាជាមួយតំណាងផ្ទាល់របស់ព្រះអង្គគឺឯកឧត្តម ប៉ែន នុត និងឯកឧត្តម សម សារី ជាជំនួយក្នុងកិច្ចចរចានោះផង[7]។

៦ ការចរចានៅប៉ារីស បានឈានដល់សំណើរមួយ ដែលធ្វើឡើងដោយមានប្រទេសបារាំង យល់ព្រមផ្ដល់សម្បទានដ៏សំខាន់ខ្លះដល់កម្ពុជា ។

**⇨នៅក្នុងប្រទេស**

តាមសន្ធិសញ្ញាបារាំង-កម្ពុជា ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៤៩ បារាំងបានទទួលស្គាល់តាមផ្លូវច្បាប់ នូវឯករាជ្យនៅកម្ពុជា។ ដូចដែលយើងធ្លាប់បានដឹងរួចមកហើយ តាមសេចក្ដីប្រកាសថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៥២ ព្រះករុណាសម្ដេចព្រះ **នរោត្តម សីហនុ** បានសន្យាជាឱឡារិកចំពោះប្រជារាស្ត្ររបស់ព្រះអង្គថា ព្រះអង្គនឹងដណ្ដើមយកឯករាជ្យទាំងស្រុងនេះដើម្បីមាតុភូមិក្នុងរយៈពេល៣ឆ្នាំយ៉ាងយូរបំផុត។ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៥៣ ឯកឧត្តម ប៉ែន នុត បានអញ្ជើញវិលត្រឡប់មកកម្ពុជាវិញ ដើម្បីទូលថ្វាយព្រះមហាក្សត្រអំពីលទ្ធផលដែលទទួលបាននៅប៉ារីស។ ព្រះករុណាសម្ដេចព្រះ **នរោត្តម សីហនុ** ក៏បានយាងមកកាន់រាជធានីភ្នំពេញ នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៥៣ ដើម្បីជួបជាមួយសហសេវិក និងនាយករដ្ឋមន្ត្រីរបស់ព្រះអង្គ។ ដូច្នេះចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៥៣ ក្រោយពេលត្រឡប់មកពីក្រុងបាងកកវិញ ព្រះមហាក្សត្របានគង់នៅ«តំបន់ស្វយ័ត» គឺខេត្តសៀមរាប បាត់ដំបង កំពង់ធំ និងថែមទាំងកំណត់ថាមិនយាងមកភ្នំពេញវិញទេ បើមិនបានឯករាជ្យបរិបូណ៌ជូនជាតិ។ នៅទីនោះព្រះអង្គបានរៀបចំផែនការជាមួយឯកឧត្តម ប៉ែន នុត (រដ្ឋមន្ត្រីទី១) និងឯកឧត្តម ប្រាក់ ប្រាព្រឿង រដ្ឋលេខាធិការរងក្រសួងក្រុមព្រះនគរបាលជាតិ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៥៣ ដែលហៅថា **«ផែនការសីហនុ»**។



រូបភាពព្រះរាជសកម្មភាពយ៉ាងលំបាកក្នុងព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ

---

7 ប្រវត្តិសង្ខេប នៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់ប្រទេសលម្ពុជា ឆ្នាំ១៩៥៦, ទំព័រទី៤

ព្រះរាជសារថ្លែងនៅបាត់ដំបង នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥៣ ក្នុងផែនការសីហនុនោះ គឺចង់ឱ្យប្រជាពលរដ្ឋប្រុសស្រី គ្រោកឈរឡើងកាន់អាវុធតស៊ូ ដើម្បីទាមទារឯករាជ្យបរិបូណ៌។ ផែនការ សីហនុ គឺការកេណ្ឌជីវពល (កម្លាំងរស់) របស់ជាតិ ដែលមាន៥ កង៖ ១-កងប្រចាំខេត្ត ២-កងធ្នូក់ ៣-កងប្រចាំឃុំ ៤-កងនារីក្លាហាន និង ៥-កងសង្គ្រោះ និងមាន២ក្រុមទៀត: (១)-ក្រុមស្បៀងអាហារ និង (២)-ក្រុមចម្រៀងកងទ័ព។

ឯករាជ្យជាតិនៃកម្ពុជា ប្រៀបជាទោចក្រយាន ដែលត្រូវមានកង់មុខនិងកង់ក្រោយ សម្តេចព្រះ **នរោត្តម សីហនុ** ធ្លាប់មានព្រះបន្ទូល៖ កង់មុខគឺ"នយោបាយ" ឯកង់ក្រោយគឺ"សេដ្ឋកិច្ច"កង់ទាំងពីរកង់មុខនិងកង់ក្រោយនៃទោចក្រយាន គឺវាមានទំនាក់ទំនងនឹងគ្នាមិនអាចមានមួយអត់មួយឡើយ ផ្ទុយទៅវិញបើគ្មានកង់ទាំងពីរនោះទេ គឺមិនអាចជិះទៅមុខបានឡើយ ។

បើយើងមើលទៅលើភូមិសាស្ត្រនយោបាយ របស់សាកលលោកគឺសង្គ្រាមលោកលើកទី១និងលើកទី២ បានធ្វើឱ្យប្រទេសមហាអំណាចធំៗដែលត្រួតត្រាគេ មានការថមថយនូវឥទ្ធិពល ពេលនោះហើយដែលនាំឱ្យមានការផ្ទុះឡើងនូវចលនាទាមទារឯករាជ្យទូទាំងពិភពលោក ពិសេសនៅក្រោយសង្គ្រាមលោកលើកទី២។ កម្ពុជាជាប្រទេសនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ក៏បានធ្វើការទាមទារឯករាជ្យនឹងគេដែរ គឺមិនត្រូវការនៅក្រោមការត្រួតត្រារបស់បារាំងតទៅទៀត។ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គបានចាប់ផ្តើមធ្វើព្រះរាជបូជនីយកិច្ចចាប់តាំងពីឆ្នាំ១៩៤៥ និងបន្តរហូតដល់ឆ្នាំ១៩៥៣ ទើបសម្រេចឈានទៅរកភាពជោគជ័យ សម្រាប់ជូនប្រទេសជាតិ។ ចាប់ពីឆ្នាំ១៩៥២ ដល់ឆ្នាំ១៩៥៣ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គយាងបំពេញព្រះរាជបូជនីយកិច្ចទាមទារកេតនភណ្ឌឯករាជ្យ ១០០ភាគរយជូនជាតិមាតុភូមិ[8]។ សម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់បានសន្យាយ៉ាងឱឡារិក នៅក្នុងព្រះសុន្ទរកថាមួយដែលទ្រង់បានថ្លែង នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៥៣ ពីព្រះទីនាំងចន្ទឆាយាថា «ព្រះអង្គនឹងបូជាជីវិត ដើម្បីដណ្តើមយកឯករាជ្យឱ្យបាន ១០០ភាគរយ»។ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥៣ ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់បានភៀសព្រះកាយទៅប្រទេសថៃ

[8] សន្និសីទ ស្តីអំពីព្រះរាជ្យបូជនីយកិច្ចទាមទារឯករាជ្យ ជូនប្រទេសកម្ពុជា ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦៧ ទំព័ទី២

ក្រោយពីមានសេចក្តីប្រកាសមួយ ដែលទាក់ទាញពិភពលោក ស្តីពីការមិនពេញចិត្ត និងបំណងប្រាថ្នាស្របច្បាប់របស់ប្រជាជាតិខ្មែរ។ ព្រះករុណាសម្តេចព្រះ **នរោត្តម សីហនុ** ទ្រង់បានប្រកាសថា ព្រះអង្គនឹងចូលរាជធានីភ្នំពេញវិញ នៅពេលណាបារាំងព្រមផ្ទេរមកឱ្យប្រទេសកម្ពុជាវិញ នូវកេតនភ័ណ្ឌចុងក្រោយនៃឯករាជ្យ។ ព្រះអង្គបានបង្កើតកងកម្លាំងជីវពល និង នារីក្លាហាន ដែលក្រោយមកកម្លាំងនៃចលនានេះ មានតួនាទីយ៉ាងធំធេងសម្រាប់ប្រទេសជាតិ។



កងកម្លាំងជីវពលនារីក្លាហាន

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ គឺ៨ខែមុនសន្និសីទនៅក្រុងហ្សឺណែវ នៅមុខព្រះបរមរាជវាំង មានធ្វើព្រះរាជពិធី ជាសញ្ញានៃការដែលប្រទេសបារាំងដកអំណាចរបស់ខ្លួន ចាកចេញផុតស្រឡះពីប្រទេសកម្ពុជា។ លោកឧត្តមសេនីយ៍ ដឺឡង់ក្លាត បានប្រគល់យ៉ាងមហោឡារិកនូវអំណាចបញ្ជាការរបស់ខ្លួនថ្វាយចំពោះសម្តេចព្រះ **នរោត្តម សីហនុ**។ កងកម្លាំងនិងសេនាធិការសឹកបារាំងក៏បានថយចេញពីប្រទេសកម្ពុជា។ តាំងពីពេលនោះមកឯករាជ្យរបស់ជាតិខ្មែរ បានក្លាយជាឯករាជ្យដ៏ជាក់លាក់បរិបូណ៌។ វិបត្តិរវាងកម្ពុជានិងបារាំងក៏បានផុតរលត់ ភាពស្អុះស្អាប់ដែលកើតមានឡើង ក្នុងមិត្តភាពខ្មែរបារាំង បានរសាយបាត់អស់។

ដោយស្នាព្រះហស្តដ៏ឧត្តុង្គឧត្តមរបស់ព្រះអង្គ ព្រះរាជាណាចក្រកម្ពុជា បានទទួលឯករាជ្យទាំងស្រុងពីសាធារណរដ្ឋបារាំង។ មហាជោគជ័យដ៏ត្រចះត្រចង់នេះ ធ្វើឱ្យប្រជារាស្ត្រកម្ពុជាទូទាំងប្រទេស បានថ្វាយព្រះកិត្តិនាមព្រះអង្គជា «ព្រះមហាវីរបុរសជាតិ ព្រះបិតាឯករាជ្យជាតិ»។



រូបភាពព្រះរាជសកម្មភាពរបស់សម្តេចព្រះ នរោត្តម សីហនុ ក្នុងព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ

## ៤.គុណតម្លៃនៃបុណ្យឯករាជ្យជាតិ មកលើយុវនារីនិងយុវជនសម័យបច្ចុប្បន្ន

*បុព្វហេតុនាំឱ្យមានការទាមទារឯករាជ្យ? វាជាការពិតហើយមេដឹកនាំប្រទេសមួយ ស្ថិតនៅក្រោមរបស់មេដឹកនាំរបស់ប្រទេសដ៏ទៃទៀត មិនមែនជាការងាយស្រួល គឺមិនអាចធ្វើអ្វីសម្រេចដោយខ្លួនឯង។ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះអង្គមានព្រះបន្ទូលថា នៅពេលដែលបារាំងដណ្តើមអំណាចពីព្រះមហាក្សត្រខ្មែរនៅឆ្នាំ១៨៩៧ ព្រះមហាក្សត្រខ្មែរបានត្រឹមតែជាម៉ាស៊ីនចុះហត្ថលេខា គឺមិនជាការងាយស្រួលទេ។ ដូច្នេះត្រូវទាមទារឯករាជ្យ មិនស្ថិតនៅក្រោមការត្រួតត្រារបស់ប្រទេសណាទេ។ សម្តេចព្រះ **នរោត្តម សីហនុ** ក៏ធ្លាប់មានព្រះបន្ទូលផងដែរថា ឯករាជ្យមានពីរ គឺឯករាជ្យនយោបាយ និងឯករាជ្យសេដ្ឋកិច្ច ទាំងពីរនេះពិតជាមានសារៈសំខាន់ មិនអាចមានមួយអត់មួយឡើយ។*

*ឯករាជ្យជាមូលដ្ឋានធំមួយ សម្រាប់បើកសករាជថ្មីឱ្យប្រជាជាតិមួយ ដែលមានគេនៅគ្រប់គ្រងពីលើធ្វើជម្ទោះ។ ពេលបានទទួលឯករាជ្យប្រៀបបីដូច គេទម្លាក់អំរែកឱ្យយើងរែកខ្លួនឯង ដែលជារឿងសំខាន់ក្នុងការទទួលខុសត្រូវ។ មានឯករាជ្យមិនមែនមានអ្វីៗទាំងអស់ទេ ឯករាជ្យឆ្នាំ១៩៥៣ ជាឯករាជ្យខាងនយោបាយ គឺនៅមិនទាន់គ្រប់គ្រាន់នោះទេនៅខ្វះខាងផ្នែកសេដ្ឋកិច្ច ទើបក្រោយមកសម្តេចព្រះ **នរោត្តម សីហនុ** ចាប់ផ្តើមអភិវឌ្ឍន៍ប្រទេសជាតិ។*

## គុណតម្លៃសម្រាប់យុវជនចំពោះឯករាជ្យ

*យើងបានឯករាជ្យហើយ ពិសេសនយោបាយ ឈ្នះ ឈ្នះ នៅឆ្នាំ១៩៩៨ យើងមានសុខសន្តិភាព សន្តិភាពដែលបានមកនោះគឺរីកចម្រើនជឿនលឿនណាស់ ដូច្នេះយើងត្រូវថែរក្សាសន្តិភាព ឱ្យមាននិរន្តរភាព កុំឱ្យក្រឡាប់ចាក់ដូច ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ យើងត្រូវពង្រឹងលទ្ធភាពឈរលើមូលដ្ឋានសុខដុមភាពមហាគ្រួសារខ្មែរ ពោលគឺការរស់នៅដោយមានសុខដុមរម្យនា ជាមួយគ្នាទើបយើងអាចប្រមូលកម្លាំងជាតិ កសាងបានឯកភាពជាតិ។*

*យុវជនជាអ្នកបន្តវេន ត្រូវដឹងថា ក្រុមចាស់ៗមិនអាចនៅយូរទៀតទេ គឺយើងត្រូវចេះរៀបចំខ្លួន ត្រៀមខ្លួនដើម្បីរែកបន្តពីរៀមច្បងយើងចាស់ៗ ដែលទម្លាក់មកឱ្យ។ បើយើងត្រៀមខ្លួនបានល្អគឺយើងរែករួច តែបើយើងមិនបានត្រៀមខ្លួនទេពិតជាមិនអាចរែករួចឡើយ។ ត្រូវស្គាល់អតីតកាលប្រវត្តិសាស្ត្រជាតិយើង ព្រោះវាជាមេរៀនសម្រាប់បច្ចុប្បន្ន។*

*ស្នាព្រះហស្តដ៏វិសេសវិសាល របស់សម្តេចព្រះ **នរោត្តម សីហនុ** ដែលព្រះអង្គជា*

ព្រះបិតាឯករាជ្យជាតិរបស់យើង ហើយយើងបានទទួលនូវមរតកនេះជាបន្ត និងថែមទាំងសុខសន្តិភាពពេញលេញ គឺរស់ក្រោមម្លប់សន្តិភាពដែលជាឱកាស ឱ្យកូនខ្មែរជាអ្នកបន្តវេនរៀបចំខ្លួនឱ្យបានល្អក្នុងការបន្តវេន។ ការរៀបចំខ្លួនឱ្យបានល្អ គឺការបង្កើនសមត្ថភាពក្នុងការយល់ដឹងអំពីតម្លៃនៃជាតិរបស់យើង អំពីវប្បធម៌ជាតិ អំពីប្រពៃណីជាតិ មូលដ្ឋានទស្សនវិជ្ជាជាតិ គឺត្រូវយល់ដឹងទាំងអស់ ដើម្បីរៀបចំខ្លួនឱ្យល្អនៅក្នុងសតវត្សរ៍ទី២១ ដែលជាសតវត្សរ៍នៃវប្បធម៌សន្តិភាព។ វប្បធម៌សន្តិភាពបានបង្កើនសមត្ថភាពឱ្យបានច្បាស់លាស់ដើម្បីបន្តវេន និងដើម្បីជានាប្រកបដោយនិរន្តរភាព។

បើទោះបីព្រះមហាវីរក្សត្រ ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ជាតួអង្គដ៏សំខាន់ក្នុងការតស៊ូទាមទារឯករាជ្យពីប្រទេសបារាំង បានយាងចូលទិវង្គតអស់រយៈពេល ១៣ឆ្នាំ(២០១២-២០២៥) ទៅហើយក្តី តែព្រះស្នាព្រះហស្តដ៏ជាញជ័យក្នុងការនាំមកនូវសិទ្ធិសេរីភាពពីប្រទេសបារាំង បានធ្វើឱ្យប្រជារាស្ត្ររបស់ព្រះអង្គនៅតែចងចាំក្នុងក្រអៅបេះដូងមិនអាចបំភ្លេចបានឡើយនូវព្រះរាជព្រះបូជនីយកិច្ចដ៏ឧត្តុងឧត្តមរបស់ព្រះអង្គ។

## ឯកសារយោង


១.សម្តេចព្រះ នរោត្តម សីហនុ(ឆ្នាំ២០០៥) រាជសកម្មភាពដើម្បីឯករាជ្យបរិបូណ៌នៃកម្ពុជាពីទស្សវត្សរ៍១៩៤០-១៩៥០ បោះពុម្ពលើកទី២ឆ្នាំ២០០៥(ផ្សាយរបស់ឥន្ទ្រទេវី)

២.រោងពុម្ពពន្លឺខ្មែរ ឆ្នាំ២០១៣ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ឥស្សរជនអមតៈ

៣.ប្រវត្តិសង្ខេប ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យនៅកម្ពុជា របស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ភ្នំពេញ២០០៣

៤.ប្រវត្តិសង្ខេបនៃព្រះរាជបេសកកម្មប្រយុទ្ធទាមទារឯករាជ្យសម្រាប់កម្ពុជា ភ្នំពេញឆ្នាំ១៩៥៦

៥.Boigraphie de Son Altesse Royale Samdech Preah NORODOM SIHANUK Upayuvareach Ex-Roi du Cambodge

៦.ផ្សាយចេញពីក្រសួងឃោសនាការភ្នំពេញ សន្និសីទ ស្តីអំពី ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យជូនប្រទេសកម្ពុជា ដែល ឧត្តមសេនីយឯក លន់ នល់ បានធ្វើចំពោះមេដឹកនាំទាំងឡាយនៃយុវជនរាជសង្គមនិយមខ្មែរ ភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៦៧

៧.ព្រះរាជសាសន៍ សម្តេចព្រះ នរោត្តម សីហនុ ឧបយុវរាជ នាយករដ្ឋមន្ត្រី ទ្រង់ថ្លែងក្នុងឱកាសពិធីបុណ្យរំលឹកឯករាជ្យជាតិប្រចាំឆ្នាំទី៥ កាលពីថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៨

៨.សន្និសីទ ស្តីអំពីព្រះរាជ្យបូជនីយកិច្ចទាមទារឯករាជ្យ ជូនប្រទេសកម្ពុជា ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៦៧